**ប្រការ ២ :** រាល់ទំនាក់ទំនងពាណិជ្ជកម្មក្រៅប្រទេស នៃព្រះរាជាណាចក្រកម្ពុជា តាមផ្លូវទឹកត្រូវធ្វើតាមរយៈ កំពង់ផែក្រុងព្រះ សីហនុ ឬ កំពង់ផែរាជធានីភ្នំពេញ ។

**ប្រការ ៣ :** បញ្ញត្តិទាំងឡាយណាដែលផ្ទុយ និង សេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ និង លោកអភិបាលខេត្តកោះកុងត្រូវអនុវត្តសេចក្តីសំរេចនេះ ។

សហនាយករដ្ឋមន្ត្រី ស្តីទី

ព្រះហស្តលេខា និង ត្រា　　　　ហត្ថលេខា និង ត្រា

**នរោត្តម សិរីវុឌ្ឍ　　　　ស ខេង**

***

*រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៩៩៤*

# សារាចរ

## សារាចរលេខ ០១ ស.រ

## ស្តីពីវិធានការទប់ស្កាត់ អំពើរត់ពន្ធតាមច្រក ស្រែអំបិល ខេត្តកោះកុង

រាជរដ្ឋាភិបាលបានសង្កេតឃើញ ថា អំពើរត់ពន្ធមួយផ្នែកធំ និង បទល្មើសមួយចំនួនដែលនាំ អោយប៉ះពាល់ខូចខាត ដល់ផលប្រយោជន៍ជាតិ មានប្រភពលេចចេញពីច្រកស្រែអំបិល ខេត្តកោះកុង ។

ដើម្បីអនុវត្តអោយមានប្រសិទ្ធភាពខ្ពស់ សេចក្តីសំរេចលេខ ៣២ សសរ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៤ របស់ រាជរដ្ឋាភិបាល ស្តីពីការបិទច្រកនាំចេញ នាំចូល ស្រែអំបិល និង ដើម្បីទប់ អំពើរត់ពន្ធពីសំណាក់ឈ្មួញទុច្ចរិត និង អំពើការពារឈ្មួញរត់ពន្ធ ពីសំណាក់កងកំលាំងប្រដាប់ អាវុធគ្មានវិន័យមួយចំនួននោះ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់ ក្រសួង ស្ថាប័ន យកចិត្តទុក ដាក់អនុវត្តនូវវិធានការ សំដៅលើកំពស់ហិរញ្ញវត្ថុ សាធារណៈដូចតទៅ :

១- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សហការជាមួយក្រសួងមហាផ្ទៃ មានភារកិច្ចធ្វើការផ្សព្វផ្សាយអោយបានទូលាយ អំពីការបិទច្រកស្រែអំបិលដល់អាជីវករ ពាណិជ្ជករទាំងឡាយ ដែលធ្លាប់ប្រើប្រាស់ច្រកនេះ សំរាប់ធ្វើអាជីវកម្ម នាំចេញ - នាំចូល ទំនិញរបស់ខ្លួន ។

២- ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ត្រូវសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បី ចាត់វិធានការតាមដានត្រួតពិនិត្យសកម្មភាពរត់ពន្ធ និង បទល្មើសផ្សេងៗ ដែលលេចចេញតាមច្រកស្រែអំបិលអោយមាន ប្រសិទ្ធភាពខ្ពស់ បន្ទាប់ពីច្រកនាំចេញ នាំចូលនេះ ត្រូវបានរាជរដ្ឋាភិបាលប្រកាសអោយបិទ ។

៣- ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ ត្រូវធ្វើការណែនាំ និង មានវិធានការដាក់វិន័យចំពោះកងកំលាំងប្រដាប់អាវុធណាដែលមិនបានគោរពវិន័យ កងយោធពលខេមរភូមិន្ទ វិន័យនគរបាល ធ្វើការរត់ពន្ធ និង ការពារឈ្មួញរត់ពន្ធ ។

ក្រោយពេលទទួលបានសារាចរនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ និង ខេត្តកោះកុង ទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល លើការអនុវត្តន៍សារាចរនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

សហនាយករដ្ឋមន្ត្រី ស្តីទី

ព្រះហស្តលេខា និង ត្រា — ហត្ថលេខា និង ត្រា

**នរោត្តម សិរីវុឌ្ឍ** — **ស ខេង**

***